ថ្ងៃអង្គារ ៥កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃម៉ាឡេស៊ី ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ

***(Agreement Between the Government of the Kingdom of Cambodia and the Government of Malaysia for the Elimination of Double Taxation with Respect to Taxes on Income and the Prevention of Tax Evasion and Avoidance-DTA)***




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយសសូមជម្រាបជូនសាធារណជន ឱ្យបានជាប្រថា នាថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៩ នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមជំនួបពិភាក្សាទ្វេភាគី កម្ពុជា- ម៉ាឡេស៊ី កិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃម៉ាឡេស៊ី ស្តីពីការលុបបំបាត់ការយកពន្ធត្រួតគ្នា ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល និងការបង្ការការគេចវេះពន្ធ និងការចៀសវាងពន្ធ ត្រូវបានបញ្ចប់ការចុះហត្ថលេខា

រួចរាល់ ដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **សៃហ្វូឌីន អាប់ឌុលឡា** រដ្ឋមន្ត្រីក្រសួងការបរទេសម៉ាឡេស៊ី ក្នុងនាមរដ្ឋាភិបាលនៃម៉ាឡេស៊ី។

កិច្ចព្រមព្រៀងនេះ ជាកិច្ចព្រមព្រៀងទី៨ ដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាជាមួយយុត្តាធិការដៃគូ។ កិច្ចព្រមព្រៀងនេះ ផ្តល់អត្ថប្រយោជន៍ដល់ភាគីហត្ថលេខីលើកិច្ចការពង្រឹង កិច្ចសហប្រតិបត្តិការទ្វេភាគី ធ្វើឱ្យប្រាកដប្រជាក្នុងការកំណត់សិទ្ធិ នៃការយកពន្ធ, កំណើនមូលដ្ឋានគិតពន្ធ តាមរយៈការទាក់ទាញវិនិយោគដោយផ្ទាល់, លំហូរមូលធន, ការផ្ទេរបច្ចេកវិទ្យានិងជំនាញពីបរទេស, ការការពារនិវាសនជន ពីប្រព្រឹត្តកម្មមិនត្រឹមត្រូវពាក់ព័ន្ធនឹងពន្ធ, និងការការពារចំណូលពន្ធ ក្នុងស្រុកតាមរយៈកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងការគេចវេះពន្ធ រវាងប្រទេសទាំងពីរ។ កិច្ចព្រមព្រៀងនេះ នឹងត្រូវចូលជាធរមាន នៅកាលបរិច្ឆេទនៃការទទួលបានការជូនដំណឹងក្រោយគេអំពីការបំពេញចប់សព្វគ្រប់នូវនីតិវិធីដែលតម្រូវដោយច្បាប់ក្នុងស្រុក។

កិច្ចព្រមព្រៀងនេះគឺជាសមិទ្ធផលថ្មីមួយទៀត ក្នុងចំណោមសមិទ្ធផលសំខាន់ៗជាច្រើន ដែលរាជរដ្ឋាភិបាលនីតិកាលទីប្រាំមួយ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ ប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា សម្រេចបាន។ ព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងធ្វើការចរចាលើកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា និងការបង្ការការកិបកេងបន្លំពន្ធ ពាក់ព័ន្ធនឹងពន្ធលើប្រាក់ចំណូល ជាមួយបណ្តាប្រទេសដៃគូមួយចំនួនទៀតដូចជា ហ្វីលីពីន, កូរ៉េ, ជប៉ុន, តួកគី, និងតំបន់រដ្ឋបាលពិសេសម៉ាការ នៃសាធារណរដ្ឋប្រជាមានិតចិន ជាដើម៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ


© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ